# មេរៀនទី ១០៤៖ ដាវីឌឧទុកជីវិតឲ្យសូល

## ១ សាំយូអែល ២៦៖៥-២៥

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/xGHhVvezRO4

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/zHJWNy0_N88

**គោលបំណង៖ ព្រះជាព្រះយុត្តិធម៌។**

**ខគម្ពីរចងចាំ៖ រ៉ូម ១២៖១៩** *"ឱពួកស្ងួនភ្ងាអើយ កុំឲ្យសងសឹកឡើយ ចូរថយចេញពីសេចក្ដីកំហឹងទៅ ដ្បិតមានសេចក្ដីចែងទុកមកថា «ព្រះអម្ចាស់ ទ្រង់មានព្រះបន្ទូលថា ការសងសឹក នោះស្រេចនឹងអញ អញនឹងសងដល់គេ» ។"*

**ចំរៀង** ( *យូធូបលីង* )៖
១. យើងនឹងឈ្នះ https://youtu.be/Ba2UR8O5Rgw
២. ខ្ញុំទុកចិត្តដល់ព្រះយេស៊ូវ https://youtu.be/Vq_yln2huAM
៣. ទ្រង់ជួយឲ្យខ្ញុំសប្បាយ https://youtu.be/S6mflMXkLNc

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត** **«ស្មើភាព ឬក៏មិនស្មើភាព»**

សម្ភារៈដែលត្រូវការ៖ ចាន និងស្ករគ្រាប់មួយចំនួន





១. ចែកកុមារជា២ក្រុម
២. ដាក់ស្ករគ្រាប់មួយចំនួននៅក្នុងចាន ហើយដាក់វានៅចុងម្ខាងនៃថ្នាក់រៀន
៣. សូមពន្យល់កុមារថា នេះគឺជាការប្រណាំងដណ្ដើមយកស្ករគ្រាប់
៤. ដោយក្រុមទី១ អាចរត់ទៅយកស្ករគ្រាប់ ប៉ុន្តែក្រុមទី២ ត្រូវដើរទៅយកស្ករ គ្រាប់ ។
៥. កុមារម្នាក់ៗអាចរត់ទៅយកស្ករគ្រាប់តែ១ ហើយរត់មកកាន់ក្រុមរបស់ខ្លួនវិញ
៦. ប្រើពេល២នាទីក្នុងការលេងល្បែងនេះ
៧. បន្ទាប់ពីលេងល្បែងនេះចប់សូមសួរកុមារថា ការលេងល្បែងនេះស្មើភាពដែរឬទេ។( ទុកឲ្យកុមារជាអ្នកឆ្លើយ )
៨. ចុះប្រសិនបើក្រុមទី១ ដែលរត់ទៅយកស្ករគ្រាប់ អត់បានញុំអាហារ២ថ្ងៃហើយនោះ? តើវាស្មើភាពដែរឬទេ ដែលពួកគេត្រូវរត់ដើម្បីទៅយកស្ករគ្រាប់នោះ? (បាទ/ចាស ...ព្រោះពួកគេឃ្លាន )
៩. សូមពន្យល់កុមារថា ពេលខ្លះរឿងរ៉ាវកើតឡើងនៅក្នុងជីវិតរបស់ពួកយើង គឺមិនតែងតែយុត្តិធម៌រហូតនោះទេ ប៉ុន្តែព្រះតែងតែធ្វើអ្វីដែលត្រឹមត្រូវ និងស្មើភាព ពីព្រោះទ្រង់ជ្រាបដឹងទាំងអស់។

**៤. ការណែនាំមេរៀន**

ប្រសិនបើមិត្តភក្តិរបស់អ្នកដាល់អ្នកមួយដៃចំមុខ តើអ្នកនឹងធ្វើដូចម្ដេច? ដើម្បីឲ្យស្មើភាពគ្នា តើអ្នកគួរតែដាល់គេវិញឬយ៉ាងណា? ឬក៏ យើងចង់ឃើញមិត្តភក្តិរបស់យើងត្រូវគ្រូជាអ្នកដាល់វិញ។ យើងគឺពិតជាចង់ បាននូវការស្មើភាពចំពោះយើងភ្លាមៗ។ ប៉ុន្តែព្រះនៃយុត្តិធម៌ទ្រង់ប្រហែលជាមិនចង់ឲ្យរឿងនេះកើត

ឡើងភ្លាមៗនោះទេ។ តោះសូមឲ្យយើងបានស្វែងយល់ពីព្រះនៃយុត្តិធម៌ និងពីរបៀបដែលព្រះបានបង្ហាញទៅ ដាវីឌ នៅពេលដែលគាត់ធ្វើការសម្រេចចិត្តបានត្រឹមត្រូវ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

រឿងនៅក្នុងព្រះគម្ពីរថ្ងៃនេះ ស្តេចសូលបានមកជាមួយនឹងកងទ័ពជាច្រើនដើម្បីតាមសម្លាប់ដាវីឌ។ ស្តេចសូលចង់សម្លាប់ដាវីឌ ដោយសារគាត់ច្រណែន និងបានដឹងថា ព្រះបានជ្រើសរើសដាវីឌធ្វើជាស្តេចបន្ទាប់ជំនួសឲ្យកូនប្រុសរបស់គាត់។

នៅពេលយប់ជ្រៅ ដាវីឌ និងទាហានរបស់គាត់ម្នាក់ឈ្មោះ អ័ប៊ីសាយ បានបន្លំខ្លួនចូលទៅក្នុងទីបោះទ័ពរបស់ស្តេច សូល។ ដាវីឌ បានឃើញថា ស្តេចសូលកំពុងលង់លក់ជាខ្លាំង ជាមួយនឹងលំពែងចាក់ជាប់ដីជិតក្បាលដំណេករបស់គាត់។ អ័ប៊ីសាយ បានប្រាប់ទៅដាវីឌថា គាត់គួរតែសម្លាប់ សូលព្រោះសូលតែងតែព្យាយាមសម្លាប់ដាវីឌរហូតមក។ អ័ប៊ីសាយ បានគិតថា វាជារឿងស្មើភាព។ ហើយដាវីឌ នឹងក្លាយទៅជាស្តេចបន្ទាប់!

ប៉ុន្តែដាវីឌបាននិយាយថា សូលគឺជាស្តេចដែលព្រះបានចាក់ប្រេងតាំង ហើយគាត់មិនចង់សម្លាប់មនុស្សដែលព្រះបានរើសតាំងនោះទេ។ ដាវីឌក៏បានដឹងដែលថា ព្រះតែងតែធ្វើនូវអ្វីដែលត្រឹមត្រូវ ហើយគាត់បានដឹងថា ព្រះនឹងដាក់ទោសសូលនៅពេលដែលពេលវេលារបស់ទ្រង់មកដល់។ លើសពីនេះទៅទៀត ដាវីឌដឹងថា ការដែលសម្លាប់សូលមិនមែនជាផ្លូវដែលត្រឹមត្រូវ ក្នុងការឡើងធ្វើជាស្តេចបន្ទាប់របស់អ៊ីស្រាអែលនោះទេ។ ដូច្នេះជំនួសឲ្យការសម្លាប់ស្តេចសូល ដាវីឌបានយកលំពែង និងក្អមទឹករបស់សូល ហើយចេញទៅ។

ដាវីឌ ក៏បានឡើងទៅលើទីទួលខ្ពស់មួយ ហើយបានប្រាប់ទៅសូលថា ខ្ញុំគឺអាចសម្លាប់ទ្រង់បាន ប៉ុន្តែយើងមិនធ្វើដូច្នេះនោះទេ ពីព្រោះទ្រង់គឺជាអ្នកដែលព្រះបានចាក់ប្រេងតាំងឲ្យ។ ដាវីឌបានបង្ហាញ លំពែងរបស់សូល ហើយបានប្រាប់ឲ្យមេទ័ពរបស់សូលម្នាក់ឡើងទៅយក ដូច្នេះគាត់អាចសងលំពែងនោះដល់សូលវិញបាន។ នៅពេលដែលសូលបានឮដូច្នេះ គាត់បានដឹងខ្លួនខុសដែលព្យាយាមសម្លាប់ដាវីឌ ហើយគាត់ក៏បានសម្រេចចិត្តចុះចេញពីដំណែង។

អ្នកប្រហែលជាគិតថា វាជាការស្មើភាពគ្នាដែលដាវីឌគួរតែសម្លាប់ស្តេចសូល ព្រោះថាសូលក៏ព្យាយាមសម្លាប់ដាវីឌដែរ។ ដូចជា អ័ប៊ីសាយដែរ អ្នកប្រហែលជាគិតថា ព្រះបានឲ្យឱកាសដល់ដាវីឌក្នុងការសម្លាប់ស្តេចសូល ដើម្បីឲ្យស្មើភាពគ្នា។ ប៉ុន្តែ ដាវីឌមិនបានធ្វើអំពើបាបដោយការសម្លាប់ស្តេចសូលនោះទេ។ ហើយដោយព្រោះតែដាវីឌ ទុកចិត្តលើព្រះដែលតែងតែផ្តល់នូវការស្មើភាពនោះ ព្រះក៏បានលើកដាវីឌ ឲ្យធ្វើជាស្តេចដ៏ល្អមួយសម្រាប់សាសន៍អ៊ីស្រាអែល។

ពេលខ្លះ យុត្តិធម៌ដែលបានមកពីព្រះ យើងមិនងាយស្រួលក្នុងការមើលឃើញនោះទេ ពីព្រោះយើងចង់បានតែការស្មើភាពគ្នាដែលកើតឡើងភ្លាមៗតែប៉ុណ្ណោះ - ការតបស្នង និងដាក់ទោសចំពោះកំហុសនោះភ្លាមៗនោះឯង។ ប៉ុន្តែព្រះដែលទតឃើញអ្វីៗទាំងអស់ ហើយដឹងគ្រប់យ៉ាងគឺយុត្តិធម៌សម្រាប់មនុស្សទាំងអស់ ទោះជាយើងមិនអាចមើលឃើញក៏ដោយ។ មនុស្សគឺត្រូវប្រើពេលវេលាយូរក្នុងការមើលឲ្យឃើញពីយុត្តិធម៌របស់ព្រះ។ ក៏ដូចជា ដាវីឌដែរ យើងគួរតែទុកចិត្តនូវភាពយុត្តិធម៌របស់ទ្រង់ ព្រោះវាប្រសើរជាងការស្មើភាព ដែលយើងយល់ឃើញ។

## ៦. សំនួរពិភាក្សា

១. តើស្ដេចសូលនិងទាហានរបស់គាត់មកដើម្បីអ្វី? *(ដើម្បីសម្លាប់ដាវីឌ)*

២. តើអ័បីសាយ ដែលជាមិត្តភ័ក្តិរបស់ដាវីឌ បានប្រាប់អ្វីដល់ដាវីឌនៅពេលដែលពួកគេរកឃើញស្ដេចសូល កំពុងដេកនោះ? *(សម្លាប់ស្ដេចសូល)*

៣. ហេតុអ្វីបានជាដាវីឌមិនសម្លាប់ស្ដេចសូល? *(១. ព្រោះសូលជាមនុស្សដែលព្រះរើសតាំង ២. ព្រះចង់ប្រាប់ដាវីឌដឹងថា ទ្រង់នឹងដាក់ទោសសូលនៅពេលដែលពេលវេលាទ្រង់មកដល់)*

៤. តើអ្នកអាចទុកចិត្តលើសេចក្ដីយុត្តិធម៌របស់ព្រះបានដោយរបៀបណា នៅពេលដែលរឿងរ៉ាវកើតឡើងមើលទៅហាក់ដូចជាមិនស្មើភាពនោះ?
*(ព្រះគឺជាម្នាក់ដែលដឹងគ្រប់កិច្ចការទាំងអស់ ហើយទ្រង់នឹងធ្វើការនៅពេលវេលារបស់ទ្រង់មកដល់)*

## ៧. ល្បែងកំសាន្ត «ប្រកួតបាល់បោះ»

សម្ភារៈដែលត្រូវការៈ បាល់១កៅអី២



១. ចែកកុមារជា២ក្រុមស្មើគ្នា

២. ជ្រើសរើសកុមារ៣នាក់ពីក្រុមនីមួយៗ។ ឲ្យកុមារម្នាក់ឈរនៅលើកៅអី កុមារម្នាក់ទៀតជួយទប់កៅអី។ ហើយកុមារទី៣ត្រូវទៅឈរពីមុខកៅអីក្រុមមួយទៀត ដើម្បីជួយការពារមិនឲ្យក្រុមគេចាប់បាល់បាន។ ហើយកុមារផ្សេងទៀតត្រូវឈរពាសពេញថ្នាក់រៀន។

៣. គ្រូនឹងបោះបាល់ទៅលើ ហើយកុមារដែលមកពីក្រុមទាំងពីរត្រូវរត់មកដណ្ដើមបាល់នោះ ហើយបោះវាទៅឲ្យអ្នកដែលនៅឈរលើកៅអីមកពីក្រុមរបស់គាត់។ ក្រុមនណាដែលអាចចាប់បាល់បានច្រើនជាងក្រុមនោះនឹងឈ្នះល្បែងនេះ។

៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ពួកគេលេងល្បែងនេះដោយភាពត្រឹមត្រូវ ដោយមិនប្រើល្បិចអ្វីទាំងអស់។ ពីព្រោះព្រះនៃយើងទ្រង់យុត្តិធម៌ វាជារឿងសំខាន់សម្រាប់យើង ដើម្បីឱ្យមានភាពយុត្តិធម៌ និងត្រឹមត្រូវផងដែរ។

## ៨. ខគម្ពីរចងចាំ

**រ៉ូម ១២៖១៩** *"ឱពួកស្ងួនភ្ងាអើយ កុំឲ្យសងសឹកឡើយ ចូរថយចេញពីសេចក្ដីកំហឹងទៅ ដ្បិតមានសេចក្ដីចែងទុកមកថា «ព្រះអម្ចាស់ ទ្រង់មានព្រះបន្ទូលថា ការសងសឹកនោះស្រេចនឹងអញ អញនឹងសងដល់គេ»។"*

## ៩. ហាត្ថកម្ម

សូមផាត់ពណ៌ "ដាវីឌទុកជីវិតឲ្យសូល" សូមមើលនៅទំព័រខាងក្រោម។

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូៈ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
សូលព្យាយាមសម្លាប់ដាវីឌម្ដងហើយម្ដងទៀត។ ប៉ុន្តែ នៅពេលដែលដាវីឌមានឱកាសសម្លាប់សូល គាត់បានបដិសេធ។ តើអ្នកមានអារម្មណ៍យ៉ាងណាចំពោះអ្នកដែលបង្កើតរឿងលំបាកសម្រាប់អ្នក? តើអារម្មណ៍ទាំងនោះគាប់ព្រះហឫទ័យព្រះទេ? ដោយសេចក្ដីស្រឡាញ់របស់ព្រះនៅក្នុងចិត្តរបស់យើងយើងអាចស្រឡាញ់សូម្បីតែសត្រូវរបស់យើងក៏ដោយ។ ព្រះយេស៊ូវស្រឡាញ់សូម្បីតែមនុស្ស ដែលបាន បោះដែកគោលទៅលើទ្រង់ជាប់នៅលើឈើឆ្កាង។ ពេលយើងចង់ធ្វើដូចទ្រង់ យើងនឹងអាចស្រឡាញ់សូម្បីតែអ្នកដែលចង់ ធ្វើបាបយើង! ជ្រើសរើសបង្ហាញសេចក្ដីស្រឡាញ់ក្នុងសប្ដាហ៍នេះចំពោះអ្នកដែលមិនងាយស្រលាញ់។

# ដាវីឌទុកជីវិតឲ្យសូល



សូមសរសេរខគម្ពីរចងចាំ: ___________________________

___________________________

___________________________

___________________________

___________________________